# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**

*សំណុំរឿងរដ្ឋប្បវេណីលេខៈ ០៣៨*

ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលក្រមរដ្ឋប្បវេណី**

លេខៈ ១០៧/១២ "ជ"

ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០២២

*សាលាដំបូងខេត្តព្រះសីហនុបានបញ្ចប់ការទាញហេតុផល ដោយផ្ទាល់មាត់នៅថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០២២ ។*

*ដោយមានសមាសភាពៈ*

១.លោក [redacted] *ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ*

២.លោក [redacted] *ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ*

រវាងដើមចោទៈ ឈ្មោះ [redacted] ប៊ុនឡេក ភេទប្រុស អាយុ ៤៧ ឆ្នាំ មានអាសយដ្ឋាននៅ [redacted] ។

ដោយមានលោកស្រីមេធាវី [redacted] លោកស្រីមេធាវី [redacted] លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ មានអាសយដ្ឋានការិយាល័យផ្ទះលេខៈ [redacted] ។

និងចុងចម្លើយៈ ឈ្មោះ [redacted] វដ្ឋា ភេទស្រី អាយុ ៦២ ឆ្នាំ មានអាសយដ្ឋាន [redacted] ។

### អង្គហេតុ និងចំណុចវិវាទៈ

១-ខ្លឹមសារ នៃសាលក្រមដែលទាមទារដោយដើមចោទៈ

១.១-សុំទាមទារប្រាក់ចំនួន USD ១២,០០០(ដប់ពីរពាន់)ដុល្លាអាមេរិក ។

១.២-សុំឲ្យអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១ ។

១.៣-សុំឲ្យចុងចម្លើយសងជម្ងឺចិត្តចំនួន USD ៣០,០០០(សាមសិបពាន់)ដុល្លាអាមេរិក ។

១.៤-សេវាមេធាវីចំនួន USD ១០,០០០(ដប់ពាន់)ដុល្លាអាមេរិក ។

១.៥-ពន្ធលើពាក្យបណ្តឹង និងពន្ធផ្សេងៗជាបន្ទុករបស់ចុងចម្លើយ ។

២-ការពន្យល់ត្រួសអំពីរឿងក្តីៈ

កាលពីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ដើមចោទបានទិញដីមួយកន្លែងទំហំ ២១ ម៉ែត្រ គុណនឹង ៤២ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងតម្លៃ USD ១២[illegible]

ពីរពាន់)ដុល្លាអាមេរិក ហើយនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧ ចុងចម្លើយបានផ្ទេរកម្មសិទ្ធិដែលមានចុះហត្ថលេខាដោយមេឃុំបិតត្រាំងមកឲ្យដើមចោទទៀត ។ ក្រោយមកស្រាប់តែចុងចម្លើយបានលក់ដីនោះទៅឲ្យអ្នកដទៃ ដោយពុំមានការយល់ព្រមពីដើមចោទ ហើយចុងចម្លើយក៏ពុំព្រមសងប្រាក់ USD ១២,០០០(ដប់ពីរពាន់)ដុល្លាអាមេរិក មកឲ្យដើមចោទទៀត ទើបធ្វើឲ្យដើមចោទដាក់ពាក្យបណ្ដឹងមកសាលាដំបូងខេត្តព្រះសីហនុតែម្ដង ។

៣-ការអះអាងរបស់ភាគី:

-ការអះអាងរបស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ: ខ្លួនសូមរក្សាសេចក្ដីថ្លែងការណ៍ដូចនៅក្នុងនីតិវិធីត្រៀមទាញហេតុផលលើកទីមួយ និងនីតិវិធីត្រៀមទាញហេតុផលលើកទីពីរនៅដដែល ដោយឥតមានការកែប្រែអ្វីឡើយ។

ទាក់ទងនឹងការចុងចម្លើយលើកឡើង គ្រាន់តែអូសបន្លាយពេលវេលាតែប៉ុណ្ណោះ នៅក្នុងកិច្ចសន្យាសងប្រាក់នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលសន្យាសងជាពីរដំណាក់កាលចំនួន USD ៦,០០០(ប្រាំមួយពាន់) ដុល្លាអាមេរិក នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៨ និងនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៩ ត្រូវសងចំនួនចំនួន USD ៦,០០០(ប្រាំមួយពាន់) ដុល្លាអាមេរិក បើចុងចម្លើយមិនមានដីសម្រាប់សងមកកូនក្ដីខ្លួនទេ ត្រូវសងប្រាក់ចំនួនបីដងនៃប្រាក់ដើមមកកូនក្ដីខ្លួន ហើយចំពោះបញ្ហាលើកទីមួយកូនក្ដីខ្លួនបានទិញដីពីចុងចម្លើយ ប៉ុន្តែមិនមានដីក៏ធ្វើកិច្ចសន្យាខ្ចីប្រាក់ ប៉ុន្តែរយៈពេលបួនឆ្នាំ ប្រាំមួយខែមកហើយ ចុងចម្លើយនៅតែមិនព្រមអនុវត្តតាមកិច្ចសន្យាសោះ ។ដោយនៅក្នុងនោះខ្លួនសូមដាក់សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ ដែលមានខ្លឹមសារដូចតទៅ:

## ១.អង្គហេតុ

កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ កូនក្ដីខ្លួនបានទិញដីមួយកន្លែងមានទទឹងប្រវែង២១ម៉ែត្រការ៉េ និងបណ្ដោយប្រវែង ៤២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិព្រៃធៀង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងតម្លៃ USD ១២,០០០ (មួយម៉ឺនពីពាន់)ដុល្លាអាមេរិក ហើយនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ឈ្មោះ [redacted] វដ្ឋា បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី មកអោយកូនក្ដីខ្លួន ដើម្បីក្លាយទៅជាម្ចាស់ដីកាន់កាប់បន្តស្របច្បាប់ និងមានការចុះហត្ថលេខាដឹងលឺដោយលោក [redacted] គៀន មេឃុំបិតត្រាំង ។

ក្រោយមកកូនក្ដីខ្លួនបានទទួលដំណឹងថាឈ្មោះ [redacted] វដ្ឋា បានលក់ដីខាងលើនេះអោយទៅអ្នកដទៃមុននឹងយកមកលក់អោយកូនក្ដីខ្លួន ។ នៅពេលដឹងរឿងនេះភ្លាមកូនក្ដីខ្លួនបានហៅឈ្មោះ [redacted] វដ្ឋា ទៅធ្វើការដោះស្រាយគ្នានៅសាលាឃុំបិតត្រាំងដោយគាត់បានសន្យាថា នឹងប្រគល់ប្រាក់ត្រឡប់មកអោយកូនក្ដីខ្លួនវិញគ្រប់ចំនួន ហើយគាត់ក៏បានធ្វើកិច្ចសន្យាព្រមព្រៀងសងប្រាក់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីទុកជាភស្តុតាង ។

## ២.មូលហេតុដែលនាំអោយខ្លួនធ្វើសេចក្ដីថ្លែងការណ៍

២.១.កូនក្ដីខ្លួនទាមទារឲ្យឈ្មោះ [redacted] វដ្ឋា សងប្រាក់ ១២,០០០ USD (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ដោយហេតុថា៖ ចុងចម្លើយឈ្មោះ [redacted] វដ្ឋា បានយល់ព្រមសងប្រាក់ចំនួន ១២,០០០ USD (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) មកអោយកូនក្ដីខ្លួន ។យោងតាមកំណត់ហេតុនីតិវិធីត្រៀមទាញហេតុផល ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

ចុងចម្លើយបានស្នើសុំសងប្រាក់មកអោយកូនក្តីខ្លួនក្នុងមួយខែ ៥០០ USD (ប្រាំរយដុល្លាអាមេរិក) ប៉ុន្តែបើកូនក្តីខ្លួនមិនព្រមទទួលយកប្រាក់ចំនួន ៥០០(ប្រាំរយ)ដុល្លាអាមេរិក ក្នុង១ខែនោះទេ គាត់នឹងប្រគល់ដីមួយកន្លែងដែលមានទំហំ ៤ម៉ែត្រ គុណនិង ១១ម៉ែត្រ មានទីតាំងស្ថិតនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មកអោយកូនក្តីខ្លួន ។ ប៉ុន្តែនៅក្នុងកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ គាត់បែរជាលើកឡើងថាៈ សូមទុកពេលអោយគាត់រយៈពេល០៣ខែអោយគាត់បានលក់ដីខាងលើនេះ ដើម្បីយកប្រាក់មកសងកូនក្តីខ្លួនចំនួន ១២,០០០ USD (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ។ មួយវិញទៀតបើពិនិត្យទៅមើលកិច្ចសន្យាព្រមព្រៀងសងប្រាក់ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលធ្វើឡើងរវាងឈ្មោះ [redacted] វដ្ឋា និងកូនក្តីខ្លួនគឺឈ្មោះ [redacted] វដ្ឋា បានសន្យាម្តងរួចមកហើយថានឹងសងប្រាក់មកអោយកូនក្តីខ្លួនជាពីរដំណាក់កាល គឺនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ សងប្រាក់ចំនួន USD ៦,០០០(ប្រាំមួយពាន់) ដុល្លាអាមេរិក និងនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ សងប្រាក់ចំនួន USD ៦,០០០(ប្រាំមួយពាន់) ដុល្លាអាមេរិក បន្ថែមទៀត ។

យោងតាមចម្លើយរបស់ចុងចម្លើយនៅក្នុងកំណត់ហេតុនីតិវិធីត្រៀមទាញហេតុផលលើកទី១ លើកទី២ និងតាមកិច្ចសន្យាព្រមព្រៀងសងប្រាក់ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុងចម្លើយគឺតែងតែឆ្លើយទទួលស្គាល់ថាជំពាក់ប្រាក់កូនក្តីខ្លួន និងសន្យាថានឹងសងប្រាក់មកអោយកូនក្តីខ្លួន ប៉ុន្តែបើពិនិត្យទៅមើលពេលវេលានៃការសងប្រាក់ចាប់តាំងពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ រហូតមកទល់ពេលនេះគឺមានរយៈពេល០៤ឆ្នាំនិង០៦ខែកន្លងមកហើយ ដែលចុងចម្លើយបានត្រឹមតែបង្ហាញឆន្ទៈថានឹងសងប្រាក់មកអោយកូនក្តីខ្លួន ប៉ុន្តែចំពោះសកម្មភាពនៃការសងប្រាក់គឺពុំមាននោះទេ ព្រោះចុងចម្លើយគ្រាន់តែព្យាយាមនិយាយអូសបន្លាយពេលវេលានៃការសងប្រាក់មកអោយកូនក្តីខ្លួនតែប៉ុណ្ណោះ ។

**២.២.កូនក្តីខ្លួនទាមទារឲ្យអនុវត្តជាបណ្តោះអាសន្ន** ដោយហេតុថាៈ ចុងចម្លើយបានយកដីដែលបានលក់អោយអ្នកដទៃរួចហើយ យកមកលក់បន្តអោយខ្លួនក្នុងតម្លៃ ១២,០០០ USD (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ហើយខ្លួនបានប្រគល់ប្រាក់ថ្លៃទិញដីអោយគាត់គ្រប់ចំនួនអស់ហើយ។ ចំពោះអង្គហេតុក្នុងរឿងជំពាក់ប្រាក់នេះគឺជាអង្គហេតុដែលមានលក្ខណៈជាក់លាក់ពិតប្រាកដ ។

**២.៣.មូលហេតុដែលនាំឲ្យកូនក្តីខ្លួនទាមទារឲ្យចុងចម្លើយសងជម្ងឺចិត្ត** ៣៦,០០០ USD (បីម៉ឺនប្រាំមួយពាន់)ដុល្លាអាមេរិក ដោយហេតុថាៈ ភាគីចុងចម្លើយជាអ្នកបំពានលើកិច្ចសន្យាប្រាក់ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលបានធ្វើឡើងរវាងកូនក្តីខ្លួនជាមួយនិងចុងចម្លើយ។

**២.៤.មូលហេតុដែលនាំឲ្យកូនក្តីខ្លួនទាមទារ** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ដោយហេតុថាៈ ចុងចម្លើយជាអ្នកបង្កផលប៉ះពាល់ដល់កូនក្តីខ្ញុំបាទដែលកើតមកជំពាក់ប្រាក់។

**<u>៣.ភស្តុតាងជាឯកសារៈ</u>**

១.កិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ។

២.លិខិតទទួលប្រាក់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ និងចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ ។

៣.លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ។

៤.កិច្ចសន្យាព្រមព្រៀងសងប្រាក់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

-ការអះអាងរបស់ចុងចម្លើយៈ ពុំបានចូលរួមក្នុងនីតិវិធីឡើយ ប៉ុន្តែកូនស្រីចុងចម្លើយបានទទួលដីកាកោះរួចហើយ អំពីដីកាកោះ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២២ ។

# សំអាងហេតុ

១-តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ប៊ុនភ្លេក បានអះអាងថា: កាលពីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ខ្លួនបានទិញដីមួយកន្លែងមានទទឹងប្រវែង ២១ ម៉ែត្រការ៉េ គុណនឹងបណ្តោយប្រវែង ៨២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងតម្លៃ ១២,០០០ USD (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ហើយនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧ ចុងចម្លើយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី មកឲ្យខ្លួនដើម្បីក្លាយទៅជាម្ចាស់កម្មសិទ្ធិបន្តដោយស្របច្បាប់ ព្រមទាំងមានការចុះហត្ថលេខាដោយអាជ្ញាធរឃុំបិតត្រាំងទៀត ។ប៉ុន្តែក្រោយមកខ្លួនបានទទួលដំណឹងថាចុងចម្លើយបានលក់ដីខាងលើឲ្យទៅអ្នកដទៃមុននឹងយកមកលក់ឲ្យខ្លួន ។នៅពេលដែលដឹងភ្លាមខ្លួនបានហៅចុងចម្លើយទៅធ្វើការដោះស្រាយនៅសាលាឃុំបិតត្រាំង ដោយក្នុងនោះចុងចម្លើយបានសន្យាថានឹងសងប្រាក់ត្រឡប់មកខ្លួនវិញ ដោយមានកិច្ចសន្យាព្រមព្រៀងសងប្រាក់ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ។ប៉ុន្តែគិតចាប់ពីថ្ងៃចុងកិច្ចសន្យាមកដល់បច្ចុប្បន្នចុងចម្លើយពុំបានសងប្រាក់មកដើមចោទវិញឡើយ ។

២-ការអះអាងរបស់ចុងចម្លើយឈ្មោះ [redacted] វឌ្ឍា: អវត្តមាននាពេលនីតិវិធីទាញហេតុផល ប៉ុន្តែកូនស្រីរបស់ចុងចម្លើយបានទទួលដំណឹងអំពីកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលនេះរួចរាល់ហើយ ។

**៣-ផ្អែកតាមការពិនិត្យភស្តុតាងរបស់ដើមចោទ និងចុងចម្លើយ:**

-ការខ្ចីប្រាក់រវាងដើមចោទឈ្មោះ [redacted] ប៊ុនភ្លេក និងចុងចម្លើយឈ្មោះ [redacted] វឌ្ឍា គឺធ្វើឡើងតាមកិច្ចព្រមព្រៀងគូភាគី ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ការបង្ហាញឆន្ទះរបស់ដើមចោទ និងចុងចម្លើយ ហើយតាមការពិនិត្យមើលភស្តុតាងរួមមាន(កិច្ចសន្យាព្រមព្រៀងសងប្រាក់ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨, លិខិតទទួលប្រាក់ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ និងចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧) តុលាការអាចពិចារណាបានថាចុងចម្លើយបានជំពាក់ប្រាក់ចំនួន USD ១២,០០០ (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ប្រាកដមែន ។

-តាមការអះអាងរបស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានទាមទារប្រាក់ជំពាក់ថ្លៃទិញដីចំនួន USD ១២,០០០ (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ដោយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយពុំបានចូលមកបង្ហាញឆន្ទះឡើយ ប៉ុន្តែនានីតិវិធីត្រៀមទាញហេតុផលទាំងពីរលើកចុងចម្លើយបានបញ្ជាក់យ៉ាងច្បាស់ថាពិតជាបានជំពាក់ប្រាក់របស់ដើមចោទចំនួន USD ១២,០០០ (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ដោយសន្យាសង មួយខែចំនួន ៥០០(ប្រាំរយ)ដុល្លាអាមេរិក និងព្រមប្រគល់ដីជាថ្នូរនឹងកាត់ប្រាក់ជំពាក់ ហើយចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន យោងតាមភស្តុតាងនានាក្នុងសំណុំរឿង ការអះអាងរបស់អ្នកតំណាងដោយអាណត្តិដើមចោទ តុលាការអាចពិចារណាឲ្យចុងចម្លើយសងប្រាក់ចំនួន USD ១២,០០០ (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ទៅដើមចោទ ។

-ចំពោះការស្នើសុំឲ្យចុងចម្លើយសងជម្ងឺចិត្តចំនួន USD ៣០,០០០(សាមសិបពាន់)ដុល្លាអាមេរិក នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថាភាគីចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន USD ១២,០០០ (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ដែលមកដល់សព្វថ្ងៃមានរយៈពេល ០៤(បួន) ឆ្នាំ០១(មួយ)ខែមកហើយ ដែលមិនបានសងប្រាក់ទៅដើមចោទ ហើយចំពោះការទាមទារជម្ងឺចិត្តនេះ តុលាការនឹងពិចារណាទៅតាមភាពសមរម្យ។

៤-ចំណែកការទាមទារសេវាកម្មមេធាវីចំនួន USD ១០,០០០(ដប់ពាន់)ដុល្លាអាមេរិក តុលាការពិចារណាឃើញថាដើមចោទ បានពឹងពាក់មេធាវីនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ដោយនៅក្នុងរឿងនេះគប្បីតុលាការពិចារណាឲ្យចុងចម្លើយសងថ្លៃសេវាកម្មមេធាវី ទៅតាមភាពសមរម្យនូវការចំណាយទៅលើសេវាកម្មមេធាវីរបស់ដើមចោទ ។

៥-នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយពុំបានចូលរួមក្នុងនីតិវិធី ប៉ុន្តែរបាយការណ៍បញ្ជូនបានបញ្ជាក់ពីការជូនដំណឹងទៅកូនស្រីជាអ្នកទទួលជំនួស ដោយការបញ្ជូននេះធ្វើឡើងស្របតាមមាត្រា ២៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី (ការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល) ដូច្នេះតុលាការពិចារណាឃើញចុងចម្លើយបានទទួលដំណឹងរួចហើយអំពីកិច្ចនីតិវិធី ។

៦-យោងតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី(ការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន) ចំពោះការទាមទារឲ្យតុលាការអនុវត្តបណ្ដោះអាសន្នលើប្រាក់ចំនួន USD ១២,០០០ (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) តុលាការអាចពិចារណាបានលើចំណុចទី ០១ នៃសេចក្ដីសម្រេច ព្រោះចុងចម្លើយបានទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់របស់ដើមចោទ ។

៧-យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទុកនៃប្រាក់ប្រដាប់ក្ដីជារបស់ភាគីដែលចាញ់ក្ដី ។

**៨-សេចក្ដីសន្និដ្ឋាន:**

-ការទាមទាររបស់ដើមចោទ ដែលមាននៅក្នុងខ្លឹមសារនៃសាលក្រមទាមទារឲ្យតុលាការចេញមានភស្តុតាងអាចឲ្យតុលាការធ្វើការពិចារណាបាន ។

## សេចក្ដីសម្រេចបញ្ចប់

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] រដ្ឋា សងប្រាក់ចំនួន USD ១២,០០០ (ដប់ពីរពាន់)ដុល្លាអាមេរិក ទៅឲ្យដើមចោទឈ្មោះ [redacted] ប៊ុនភ្លេក ។

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] រដ្ឋា សងជម្ងឺចិត្ត និងថ្លៃសេវាកម្មច្បាប់មេធាវីចំនួន USD ៥,០០០(ប្រាំពាន់)ដុល្លាអាមេរិក ទៅឲ្យដើមចោទឈ្មោះ [redacted] ប៊ុនភ្លេក ។

៤-សាលក្រមនេះអនុវត្តជាបណ្ដោះអាសន្នលើចំណុច១ នៃសេចក្ដីសម្រេចបញ្ចប់ទោះបីមានការប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក៏ដោយ ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

៦-សាលក្រមនេះធ្វើការទាញហេតុផលនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០២២ ចាត់ទុកជាចំពោះមុខដើមចោទឈ្មោះ [redacted] ប៊ុនភ្លេក និង ចាត់ទុកជាចំពោះមុខឈ្មោះ [redacted] រដ្ឋា។

៧-ទុកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ចៅក្រម